# ប្រសិនបើសាក្សីទទួលបានការការពារពិតមែននោះ តើសាក្សីទាំងអស់នឹងទទួលបានការការពារដោយស្មើភាពគ្នាដែរឬទេ?


*ដោយ ឡូរ៉ា ម៉ាកដូណល់*

*ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩*

*ប្រែសម្រួលដោយ ខែន សុខស្រីនិត*


នាព្រឹកនេះ អង្គជំនុំជម្រះសាលាដំបូង បានបន្តស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន ជាជនរស់រានមានជីវិតពីមន្ទីរឃុំឃាំងសម្ងាត់ពីរកន្លែងគ្រប់គ្រងដោយជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ណាំ ម៉ុន បានផ្តល់សក្ខីកម្មថា គាត់បានឃើញ ឌុច វាយពូពីរនាក់របស់គាត់រហូតដល់ស្លាប់ ។ នេះគឺជាភស្តុតាងជាលើកទីមួយដែលបង្ហាញជូនចៅក្រមថា ឌុច បានសម្លាប់មនុស្សដោយផ្ទាល់ដៃ ។

នៅពេលរសៀល ចៅក្រមមានគម្រោងស្តាប់នូវសក្ខីកម្មរបស់សាក្សី ម៉ម ណៃ អតីតអ្នកនៅក្រោមបង្គាប់របស់ ឌុច ។ យ៉ាងណាមិញ ការជំទាស់ពីសំណាក់មេធាវីការពារក្តីស្តីពីបញ្ហាសិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងបានបង្អាកដំណើរការនីតិវិធី ដើម្បីប្រគល់ពេលវេលាឲ្យ ម៉ម ណៃ ស្វែងរកនូវអ្នកជំនួយផ្នែកច្បាប់ទាក់ទិននឹងបញ្ហាសិទ្ធិរបស់សាក្សីនេះ ។ ម៉ម ណៃ បាននិយាយថាបើទោះបីជាគាត់ចង់បានអ្នកតំណាងផ្នែកច្បាប់ក៏ដោយ ក៏គាត់គ្មានលទ្ធភាពនឹងរកអ្នកតំណាងឡើយ ។ ដូច្នេះហើយបានជាគាត់មិនមានអ្នកតំណាងផ្នែកច្បាប់ ។ ជាក់ស្តែង ម៉ម ណៃ មានការទទួលខុសត្រូវលើផ្នែកសួរចម្លើយកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលជាប់ឃុំនៅគុកទួលស្លែង (មន្ទីរស-២១) ។

## អតីតគ្រូពេទ្យមន្ទីរស-២១អះអាងថា ឌុច បានសម្លាប់ពូពីរនាក់របស់គាត់នឹងរនុកដែក

កាលពីថ្ងៃព្រហស្បតិ៍កន្លងផុតទៅ លោកប្រធាន និល ណុន បានសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន អស់ប្រមាណពីរ-បីម៉ោងមុននឹងផ្អាកដំណើរការនីតិវិធី ដោយសារតែ ណាំ ម៉ុន យំខ្លាំងពេកបន្ទាប់ពីបានឃើញរូបថតពាក់កណ្តាលខ្លួនរបស់ឪពុកគាត់ ។ ថ្ងៃនេះ ចៅក្រមបានបន្តសួរសំណួរទៀត ប៉ុន្តែម្តងនេះអ្នកតំណាងមកពីអង្គការដែលផ្តល់កិច្ចការគាំទ្រផ្នែកចិត្តសាស្ត្របានអង្គុយក្បែរ ណាំ ម៉ុន

ដោយដាក់ដៃនៅលើខ្លួន ឬក៏ដៃរបស់ ណាំ ម៉ុន។ ប្រសិនបើ ណាំ ម៉ុន និយាយជាមួយអ្នកតំណាង នោះ សម្លេងរបស់អ្នកទាំងពីរនឹងមិនអាចស្តាប់ឮបានទេ ។ លោកប្រធានចៅក្រមបានចាប់ផ្តើមដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះដោយភាពរួសរាយរាក់ទាក់ និងសួរ ណាំ ម៉ុន ថា «តើអ្នកសុខសប្បាយទេក្នុងថ្ងៃនេះ»? គួរឲ្យកត់សម្គាល់អាកប្បកិរិយា និងពាក្យសម្តីរបស់លោកប្រធានបានផ្លាស់ប្តូរយ៉ាងខ្លាំង ។ កាលពីពីរសប្តាហ៍មុន ដើមបណ្តឹងរដ្ឋប្បវេណីបានណែនាំសាក្សីទាំងមិនយកចិត្តទុកដាក់ដោយបង្អាប់ឲ្យសាក្សីគ្រប់គ្រងអារម្មណ៍របស់ខ្លួន និងបន្តឆ្លើយនឹងសំណួរទៀត ពីព្រោះថា ពេលវេលាមានសារសំខាន់ណាស់សម្រាប់អង្គជំនុំជម្រះនេះ ។

បន្ទាប់ពីត្រូវបានជន្លៀសចេញពីទីក្រុង ភ្នំពេញ កាលពីខែមេសា ឆ្នាំ១៩៧៥មក ក្រុមគ្រួសាររបស់ ណាំ ម៉ុន បានវិលត្រឡប់មកកាន់ទីក្រុងវិញ ។ ឪពុកម្តាយរបស់ ណាំ ម៉ុន បញ្ជូនគាត់ឲ្យរៀនវគ្គបណ្តុះបណ្តាលពេទ្យមូលដ្ឋានពីរបៀបព្យាបាលរបួស និងរបៀបប្រើប្រាស់ថ្នាំ ។ បើទោះបីជា ណាំ ម៉ុន មិនចេះអានអក្សរក៏ដោយ ក៏គាត់អាចចាំពីរបៀបប្រើប្រាស់ និងដឹងពីភាពខុសគ្នានៃថ្នាំ អាស្ពេរិន និងវីតាមីន ដោយរូបសញ្ញារបស់ថ្នាំទាំងពីរ ។ ពាក់កណ្តាលឆ្នាំ១៩៧៥ ក្នុងវ័យ១៥ឆ្នាំ ណាំ ម៉ុន បានចាប់ផ្តើមធ្វើការជាអ្នកគ្រូពេទ្យជាមួយនឹងអ្នកគ្រូពេទ្យពីរនាក់ទៀតនៅមន្ទីរស-២១ ។ កាលពីថ្ងៃព្រហស្បតិ៍ ណាំ ម៉ុន បានអះអាងថា អ្នកគ្រូពេទ្យទាំងបីនាក់រួមទាំងគាត់មានឋានៈស្មើគ្នា ប៉ុន្តែនៅថ្ងៃនេះគាត់បាននិយាយថា អ្នកគ្រូពេទ្យម្នាក់ក្នុងចំណោមអ្នកគ្រូពេទ្យទាំងបីមានឋានៈជា ប្រធានដោយមានតួនាទីទទួលយកថ្នាំពីមន្ទីរក្នុងតំបន់ និងបង្គាប់ឲ្យ ណាំ ម៉ុន ប្រើប្រាស់ថ្នាំមួយចំនួនដើម្បីកុំឲ្យអ្នកទោសស្លាប់ ដើម្បីទុកសួរចម្លើយ ។ ណាំ ម៉ុន បានព្យាបាលអ្នកទោសប្រុសស្រីដែលជាប់ឃុំនៅក្នុងអគារធំៗបួននៅក្នុងបរិវេណមន្ទីរស-២១ ។ ថ្នាំទំនើបដែលនៅសេសសល់ពីរបបមុនបានអស់ ដូច្នេះ ណាំ ម៉ុន បានចាប់ផ្តើមប្រើប្រាស់ថ្នាំបុរាណវិញម្តង ។ ឌុច បានទទួលស្គាល់ថា អ្នកគ្រូពេទ្យបានបូមយកឈាមពីអ្នកទោសមន្ទីរស-២១ដើម្បីយកមកសង្គ្រោះកងទ័ពខ្មែរក្រហម ហើយបន្ថែមលើនេះយ៉ាងហោចណាស់មានអ្នកទោសម្នាក់ត្រូវបានសម្លាប់ដើម្បីយកគ្រឿងក្នុងមកធ្វើការពិសោធន៍ ។ ណាំ ម៉ុន មិនបានដឹងពីការប្រព្រឹត្តបែបនេះឡើយ ។

ក្នុងអំឡុងពេលបំរើការជាអ្នកគ្រូពេទ្យ ឪពុក និងពូបីនាក់ទៀតរបស់ ណាំ ម៉ុន ធ្វើការឲ្យខ្មែរក្រហម ។ យ៉ាងហោចណាស់ ពូពីរនាក់របស់គាត់មានឋានៈខ្ពស់ល្មមនៅក្នុងកងយោធា ។ ហើយមានពូម្នាក់ធ្លាប់បានប្រារព្ធពិធីជប់លៀងនៅផ្ទះ ដែលកាលនោះ ណាំ ម៉ុន ធ្លាប់បានឃើញ ឌុច ចូលរួមពីរដងដែរ ។

បងប្រុសពីរនាក់របស់ ណាំ ម៉ុន គឺជាអ្នកយាមនៅមន្ទីរស-២១ ។ ណាំ ម៉ុន បានជួបជុំជាមួយគ្រួសារដើម្បីពិភាក្សាគម្រោងលួចរត់ ។ មួយរយៈខ្លីកន្លងទៅ ពូម្នាក់របស់ ណាំ ម៉ុន បានភៀសខ្លួនទៅរស់នៅសហរដ្ឋអាមេរិក ។ សព្វថ្ងៃនេះ គាត់នៅរស់រានមានជីវិតនៅឡើយទេ ។ ពីរសប្តាហ៍ក្រោយពេលដែលពូគាត់បានភៀសខ្លួនទៅ ពូពីរនាក់ផ្សេងទៀត និងឪពុករបស់ ណាំ ម៉ុន ត្រូវបានចាប់ខ្លួនភ្លាមៗ ។

ក្រោយពីការចាប់ខ្លួននៅឆ្នាំ១៩៧៧ ឪពុករបស់ ណាំ ម៉ុន ត្រូវជាប់ឃុំឃាំងនៅអគារដែល ណាំ ម៉ុន ព្យាបាលអ្នកជម្ងឺ ។ ណាំ ម៉ុន មិនអាចប្រាស្រ័យទាក់ទងជាមួយនឹងឪពុករបស់គាត់បានទេ ហើយឪពុករបស់គាត់ប្រាប់កុំឲ្យ ណាំ ម៉ុន ស្គាល់គាត់ ។ ណាំ ម៉ុន យល់ថា ការធ្វើបែបនេះគឺដើម្បីរក្សាជីវិតរបស់គាត់ ហើយក្រោយមក ណាំ ម៉ុន មិនដែលបានទៅសួរសុខទុក្ខគាត់ម្តងទៀតឡើយ ។ អស់រយៈពេលប្រាំមួយខែ ណាំ ម៉ុន ត្រូវបានអ្នកគ្រូពេទ្យម្នាក់ប្រាប់ថា បងប្រុសរបស់ ណាំ ម៉ុន ត្រូវអនុវត្តតាមបញ្ជាឲ្យបាញ់សម្លាប់ឪពុករបស់គាត់ ។ ប៉ុន្មានថ្ងៃក្រោយមក បងប្រុសរបស់ ណាំ ម៉ុន ម្នាក់នោះត្រូវបានសម្លាប់ដោយសារតែគាត់ស្ទាក់ស្ទើរមិនហ៊ានបាញ់សម្លាប់ឪពុក ។ បងប្រុសម្នាក់នោះត្រូវបានចោទថាជាខ្មាំង ។ បងប្រុសម្នាក់ទៀតរបស់ ណាំ ម៉ុន ដែលធ្វើការជាអ្នកយាមគុករួមទាំងម្តាយ និងប្អូនប្រុសរបស់គាត់ត្រូវបានចាប់ខ្លួនភ្លាមៗផងដែរ ។ បន្ទាប់ពីនេះ គាត់មិនដែលបានជួបមុខអ្នកទាំងនោះទៀតឡើយ ។

ឆ្លើយតបនឹងសំណួររបស់ព្រះរាជអាជ្ញា ណាំ ម៉ុន បានផ្តល់សក្ខីកម្មថា គាត់បានឃើញ ឌុច វាយពូទាំងពីរនាក់របស់គាត់នឹងរនុកដែកប្រវែងកន្លះម៉ែតរហូតដល់ស្លាប់ ។ ណាំ ម៉ុន បានមើលសកម្មភាពនេះពីបង្អួចដែកនៅបន្ទប់ជាន់ទីបីដែលមានចម្ងាយប្រមាណប្រាំម៉ែត្រពីអគាររបស់គាត់ ។ ណាំ ម៉ុន បានឃើញ ឌុច និងបុរសពីរនាក់ប្រដាប់ដោយកាំភ្លើងវាយពូទាំងពីររបស់គាត់ ។ គួរឲ្យចម្លែក ប៉ុន្មានថ្ងៃមុន ណាំ ម៉ុន ត្រូវបានសួរថា តើគាត់មានបានឃើញការវាយធ្វើបាបនិងសម្លាប់នៅមន្ទីរស-២១ដែរឬទេ ហើយពេលនោះ ណាំ ម៉ុន បានឆ្លើយតបថា គាត់ឃើញតែអ្នកមានរបួស ប៉ុន្តែមិនដែលឃើញការវាយធ្វើបាប និងសម្លាប់ដោយផ្ទាល់ភ្នែកទេ ។ ជាមួយគ្នានេះ ណាំ ម៉ុន ក៏បាននិយាយថាគាត់បានឃើញ ឌុច យ៉ាងហោចណាស់ម្តងក្នុងមួយសប្តាហ៍ ។ ណាំ ម៉ុន ស្គាល់ថា ឌុច គឺ«បងខាងកើត» ប៉ុន្តែមិនបានដឹងពីតួនាទីរបស់ ឌុច កាលពីពេលនោះទេ ។

បន្ទាប់ពីពូរបស់គាត់ត្រូវបានសម្លាប់ ណាំ ម៉ុន ក៏ត្រូវបានចាប់ខ្លួន និងជាប់ឃុំឃាំងនៅក្នុងបន្ទប់ឃុំអ្នកទោសមួយនៅមន្ទីរស-២១អស់រយៈពេលបីខែ ។ ក្នុងអំឡុងពេលសួរចម្លើយ ណាំ ម៉ុន បានបដិសេធថា គាត់មិនមែនជាកូនរបស់ជនក្បត់ទេដោយអះអាងថា គាត់គឺជាកូនស្រីរបស់ឪពុកម្តាយធម៌គាត់ ។ ដោយមិនដឹងពីមូលហេតុអ្វីទាំងអស់ ណាំ ម៉ុន ក៏ត្រូវបានបញ្ជូនទៅកាន់កន្លែងកសាងខ្លួនព្រៃស (មន្ទីរស-២៤) ដែលជាមន្ទីរឃុំឃាំងមួយគ្រប់គ្រងដោយ ឌុច ។

ណាំ ម៉ុន បាននិយាយថា នៅមន្ទីរស-២៤មិនមែនជាកន្លែងសម្រាប់កសាងខ្លួននោះទេ ផ្ទុយទៅវិញជា«កន្លែងសម្លាប់ស្ត្រី និងកុមារ» ។ នៅមន្ទីរស-២៤ ណាំ ម៉ុន បានបង្ហឹទ្យជីករណ្តៅធំៗសម្រាប់កប់សាកសពកូនក្មេង ។ ណាំ ម៉ុន មិនបានដឹងពីការងារដែលអ្នកទោសផ្សេងទៀតទទួលបញ្ជាឲ្យធ្វើនោះទេ ។ នៅពេលត្រូវបានសួរកាលពីថ្ងៃព្រហស្បតិ៍មុនថា តើគាត់មានដឹងថាកូនក្មេងស្លាប់ដោយរបៀបណានៅមន្ទីរស-២៤ ណាំ ម៉ុន ក៏បាននិយាយថា គាត់មិនដឹងទេ ប៉ុន្តែបានព្រួសម្លេងកូនក្មេងយំ ។ ថ្ងៃនេះ ណាំ ម៉ុន បានរៀបរាប់ពីការប្រទះឃើញសាកសពកូនក្មេងជាញឹកញាប់ និងការបោះកូនក្មេងដែលមានអាយុប្រមាណមួយ ឬពីរខួបទៅលើហើយចាក់នឹងកាំបិត ។ ណាំ ម៉ុន ត្រូវបានជាប់ឃុំនៅមន្ទីរស-២៤រយៈពេលប្រហែលបីខែមុននឹងបញ្ជូនទៅកាន់មន្ទីរឃុំឃាំងមួយទៀត ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឌុច ។ ណាំ ម៉ុន បានជាប់នៅមន្ទីរឃុំឃាំងនោះរហូតដល់ពេលដែលកងទ័ពវៀតណាមក្តោបក្តាប់ទីក្រុងភ្នំពេញ ។

ដំណើរការនីតិវិធីក្នុងថ្ងៃនេះបានដើរតួជាកត្តាគ្រើនរំឭកថា ភាពងាយស្រួលមិនអាចកើតមានទេនៅក្នុងអង្គជំនុំជម្រះនេះ ។ ខណៈពេលដែលដោះស្រាយជាមួយនឹងសាក្សីដែលមានភាពភ័យខ្លាចនិងមានបញ្ហាគានតឹងផ្លូវចិត្ត ចូលមកធ្វើសក្ខីកម្មពីបទពិសោធន៍របស់គេកាលពីសាមសិបឆ្នាំកន្លងទៅនេះ វាពិតជាលំបាកក្នុងការចង្អុលបង្ហាញពីហេតុការណ៍មួយសូម្បីតែហេតុការណ៍ធម្មតា ។ កាលពីថ្ងៃព្រហស្បតិ៍មុនខ្ញុំបានរាយការណ៍ដោយភាពជឿជាក់ថា ៖ «ដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន អាយុ៤៨ឆ្នាំ បានចូលខ្លួនមកធ្វើសក្ខីកម្មនៅក្នុងថ្ងៃនេះដើម្បីធ្វើជាតំណាងឲ្យខ្លួនគាត់ បងប្អូនប្រុសទាំងបួននាក់ ឪពុកម្តាយ និងពូពីរនាក់ទៀតរបស់គាត់ដែលត្រូវបានសម្លាប់នៅមន្ទីរស-២១» ។ ក្នុងថ្ងៃនេះសូម្បីតែសេចក្តីអធិប្បាយបែបនេះ ក៏ត្រូវបានជំទាស់ដោយចៅក្រម មេធាវីការពារក្តី និង ឌុច ដែរ ។

លោកប្រធានចៅក្រមបានកាន់កាតអត្តសញ្ញាណប័ណ្ណជាផ្លូវការរបស់ ណាំ ម៉ុន នៅក្នុងដៃដែលបញ្ជាក់ថា ណាំ ម៉ុន មានអាយុតិចជាអាយុដែលគាត់បានប្រាប់តុលាការដល់ទៅ១០ឆ្នាំ ។ ណាំ ម៉ុន បាននិយាយថា មីងរបស់គាត់បានប្រាប់អាយុខុសទៅដល់អាជ្ញាធរធ្វើអត្តសញ្ញាណប័ណ្ណដោយមិនមានការពិភាក្សាជាមួយគាត់ជាមុន ។ នៅក្នុងសំណុំឯកសារជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ណាំ ម៉ុន គាត់បានចាត់ទុកបងប្អូនបង្កើតរបស់គាត់ជាបងប្អូនជាដូនមួយ ។ រូបថតមួយសន្លឹកដែលមានសរសេរជាភាសាអង់គ្លេសដោយមេធាវីរបស់ ណាំ ម៉ុន ថា «បងប្អូនបង្កើតរបស់ខ្ញុំ»គឺជារូបថតឪពុករបស់គាត់ ។ លើសពីនេះ ណាំ ម៉ុន បានចាត់ទុក«បងប្រុសធម៌»របស់គាត់ជា«បងប្រុសបង្កើត»ដែលបណ្តាលឲ្យមានភាពច្របូកច្របល់ ។ មូលហេតុសម្រាប់ការនិយាយឈ្មោះខុស និងការមិនបានគូសបញ្ជាក់ឈ្មោះសមាជិកគ្រួសារឲ្យបានច្បាស់លាស់នៅក្នុងសំណុំឯកសារជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ណាំ ម៉ុន គឺមកពីគាត់មានភាពភ័យខ្លាចក្នុងពេលដែលចៅក្រមសួរ ។ បើទោះបីជាយើងអាចយល់បានថាសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមានភាពភ័យខ្លាចនឹងការសង់សឹកក៏ដោយ ក៏មូលហេតុជាក់លាក់ដែលបុគ្គលម្នាក់ធ្វើការសម្រេចចិត្តដោយចាត់ទុកឪពុករបស់ខ្លួនជាបងប្រុសនោះមិនអាចរកឃើញទេ ។ ក្នុងស្ថានភាពបែបនេះ ចៅក្រម និងភាគីទាំងអស់បានចំណាយពេលសែសិបនាទីដើម្បីគូសបញ្ជាក់ថា តើ ណាំ ម៉ុន មានអាយុពិតប្រាកដប៉ុន្មានឆ្នាំ គាត់មានសមាជិកប៉ុន្មាននាក់ ហើយអ្នកទាំងនោះ មានឈ្មោះពិតប្រាកដ និងឈ្មោះហៅក្រៅយ៉ាងដូចម្តេច ។ ប៉ុន្តែចុងក្រោយបង្អស់ ចម្លើយរបស់មូលហេតុទាំងនេះនៅតែមិនបានគូសបញ្ជាក់ឲ្យបានច្បាស់លាស់ដដែល ។ បទដ្ឋាននីតិវិធីរបស់ចៅក្រម គឺអនុញ្ញាតឲ្យ ឌុច ធ្វើការឆ្លើយតបនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបន្ទាប់ពីចៅក្រម ព្រះរាជអាជ្ញា មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការសួរសំណួរមុនពេលដែលមេធាវីការពារក្តីចាប់ផ្តើមសួរសំណួររបស់ខ្លួន ។ ទន្ទឹមនឹងនោះ ចៅក្រមក៏បានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីសួរសំណួរទៅកាន់ ឌុច តាមរយៈចៅក្រម ។ ណាំ ម៉ុន បានសួរថាតើ ឌុច នឹងមិនព្រមទទួលស្គាល់ការពិត និងព្រឹត្តិការណ៍ដែលគាត់បានលាតត្រដាងនៅក្នុងសក្ខីកម្មនេះមែនដែរឬទេ ។

ការឆ្លើយតបរបស់ ឌុច ដែលយើងអាចស្មានដឹងនោះគឺថា ឌុច បានទទួលស្គាល់ថា គាត់មានការទទួលខុសត្រូវចំពោះការរងទុក្ខវេទនាដែលកើតឡើងនៅក្នុងប្រទេសកម្ពុជាតាមផ្លូវ«ច្បាប់» «សតិអារម្មណ៍» និងដោយ«ខ្លួនឯង» ។ បន្ថែមលើនេះ ឌុច ក៏បានទទួលស្គាល់ថា ណាំ ម៉ុន បានរងទុក្ខវេទនាពីការបាត់បង់សមាជិកគ្រួសារទាំងអស់ ប៉ុន្តែ ឌុច មិនទទួលស្គាល់ថា ការរងទុក្ខវេទនារបស់ ណាំ ម៉ុន បានកើតឡើងនៅមន្ទីរស-២១ និងមន្ទីរស-២៤ទេ ។ ឌុច បាននិយាយថា រឿងរ៉ាវរបស់ ណាំ ម៉ុន មិន

មានលក្ខណៈស្របគ្នានឹងការពិតនោះទេ ។ ឌុច បានកត់សម្គាល់ថា ឪពុក ណាំ ម៉ុន មិនអាចធ្វើការជាអ្នក«ថតចម្លងឯកសារ»ឲ្យមន្ទីរស-២១ឡើយ ពីព្រោះថា ការងារនេះមិនមានទេនៅមន្ទីរស-២១ ។ លើសពីនេះ ឪពុក ណាំ ម៉ុន មិនមានឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកទោសឡើយ ។ ឌុច អះអាងថា នៅមន្ទីរស-២១«មិនមានគ្រូពេទ្យស្រី»ទេ ។ ឌុច បានយល់ថា វាគួរឲ្យចម្លែកដែលថា ណាំ ម៉ុន បានស្គាល់គ្រូពេទ្យស្រីពីរនាក់ និងក្រុមគ្រួសាររបស់ខ្លួននៅមន្ទីរស-២១ ប៉ុន្តែមិនបានស្គាល់ឈ្មោះបុគ្គលិកផ្សេងទៀត ។ ឌុច និយាយថា គាត់មិនមានអំណាចនឹងបញ្ជូនជនណាម្នាក់ពីមន្ទីរស-២៤ទៅកាន់មន្ទីរឃុំឃាំងផ្សេងទៀតឡើយ ។ បន្ទាប់មកទៀត ឌុច បានគូសបញ្ជាក់ថា ណាំ ម៉ុន មិនបានលើកឡើងពីការផ្លាស់ប្តូរទីតាំងរបស់មន្ទីរស-២១ដែលធ្វើឡើងក្នុងអំឡុងពេលដែល ណាំ ម៉ុន បានអះអាងថា គាត់កំពុងតែធ្វើការនៅមន្ទីរស-២១ទេ ។ ឌុច បាននិយាយថា គ្មានឯកសារណាមួយបញ្ជាក់ថា ណាំ ម៉ុន បានធ្វើជាគ្រូពេទ្យនៅមន្ទីរស-២១ឡើយ ៖ «គ្មានភស្តុតាងទាល់តែសោះ!»

ទាក់ទិននឹងរូបថតពាក់កណ្តាលខ្លួនទាំងប្រាំពីរនៃសមាជិកគ្រួសាររបស់ ណាំ ម៉ុន ដែលបានបង្ហាញឲ្យឃើញនោះ ឌុច បាននិយាយថា គាត់មិនមានតួនាទីសម្រេចទទួលស្គាល់ ឬបដិសេធរូបថតទាំងនេះទេ ពីព្រោះថា ភស្តុតាងជាឯកសារមិនមានគ្រប់គ្រាន់ដើម្បីគាំទ្រការអះអាងនេះឡើយ ។ ខណៈពេលដែលត្រូវសួរដោយចៅក្រម ខាតរ៉ាយថ៍ ថាតើ ឌុច ស្គាល់មនុស្សក្នុងរូបថតទាំងនេះដែរឬទេ ឌុច និយាយថា«មិនស្គាល់សូម្បីតែម្នាក់» ។

មេធាវីការពារក្តីជាទូទៅតែងតែនិយាយក្នុងរយៈពេលខ្លី ប៉ុន្តែថ្ងៃនេះមេធាវី ហ្វ្រង់ស័រ រូ និង ការសាវុត្ត បានចំណាយពេលសែសិបនាទីដែលខ្លួនមានធ្វើការគូសបញ្ជាក់ពីភាពខុសគ្នារវាងសក្ខីកម្មដោយផ្ទាល់មាត់របស់ ណាំ ម៉ុន នៅក្នុងថ្ងៃនេះ និងកាលពីថ្ងៃព្រហស្បតិ៍ សក្ខីកម្មផ្ទាល់មាត់ជាមួយនឹងសំណុំឯកសារជាដើមបណ្តឹងរដ្ឋប្បវេណី ធាតុពិតជាក់ស្តែងរបស់មន្ទីរស-២១ជាមួយនឹងសក្ខីកម្មរបស់គាត់ ។ ឧទាហរណ៍ មេធាវីការពារក្តីបានកត់សម្គាល់ឃើញថាមន្ទីរស-២១មិនទាន់សាងសង់នៅទីកន្លែងបច្ចុប្បន្ននេះទេរហូតមកដល់ឆ្នាំ១៩៧៦ ដែលផ្ទុយពីការអះអាងរបស់ ណាំ ម៉ុន ដែលថា នាងបានចាប់ផ្តើមធ្វើការនៅមន្ទីរស-២១ជាគ្រូពេទ្យនៅទីតាំងថ្មីនៅពាក់កណ្តាលឆ្នាំ១៩៧៥ ។ ណាំ ម៉ុន បានឆ្លើយតបភ្លាមៗថា គាត់បានចាប់ផ្តើមព្យាបាលកងទ័ពខ្មែរក្រហមដែលសម្រាកព្យាបាលនៅមន្ទីរស-២១មុនពេលមន្ទីរស-២១នេះចាប់ផ្តើមដំណើរការជាផ្លូវការ ។

*មេធាវី ការ សាវុត្ថ បានធ្វើការពិនិត្យលើការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយនិយាយលឺៗ និងដោយអាកប្បកិរិយាមិនសមរម្យ ហើយបានធ្វើសេចក្តីសន្និដ្ឋានមួយមុននឹងបញ្ចប់ការសួរសំណួររបស់ខ្លួន។ បន្ទាប់ពីមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រោកឈរជំទាស់ដោយសំណូមពរឲ្យចៅក្រម "បង្គាប់ឲ្យ ការ សាវុត្ថ គ្រប់គ្រងអារម្មណ៍ឲ្យបានល្អ" និង "ចៀសវាងការប្រើពាក្យមិនសមរម្យ" មកលោកចៅក្រមក៏បង្គាប់ឲ្យ ការ សាវុត្ថ ចៀសវាងទង្វើខុសឆ្គងទាំងនេះ។ ខណៈពេលបន្តសួរសំណួរបន្ថែមទៀត ការ សាវុត្ថ បានធ្វើសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវមួយ ហើយភ្លាមនោះចៅក្រមបានធ្វើអន្តរាគមន៍។ លោកប្រធានចៅក្រមបានប្រាប់ឲ្យ ការ សាវុត្ថ រៀបចំសំណួររបស់ខ្លួនឡើងវិញ ដើម្បីចៀសវាងការធ្វើសេចក្តីសន្និដ្ឋាដោយខ្លួនឯង។ យើងសង្ឃឹមថា ចៅក្រមនឹងបន្តត្រួតពិនិត្យលើការសួរសំណួររបស់ ការ សាវុត្ថ។*

## អ្នកសួរចម្លើយរបស់មន្ទីរស-២១ បានចូលខ្លួនមកធ្វើសក្ខីកម្មដោយមិនមានអ្នកប្រឹក្សាផ្នែកច្បាប់

*ម៉ម ណៃ អតីតអ្នកសួរចម្លើយកម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា បានចូលខ្លួនមកធ្វើសក្ខីកម្មនាពេលរសៀលនេះ ប៉ុន្តែគាត់មិនបានផ្តល់នូវសក្ខីកម្មដែលមានសារសំខាន់នោះទេ។ បន្ទាប់ពីលោកប្រធានចៅក្រមសួរសំណួរទាក់ទិននឹងប្រវត្តិរូបដូចជា ឈ្មោះ អាយុ មុខរបរ និងទីកន្លែងរស់នៅ មេធាវីអន្តរជាតិ ហ្វ្រង់ស៊័រ រ៉ូ បានលើកឡើងពីការជំទាស់របស់ខ្លួន។ ខណៈពេលដែលសាក្សីដូចជា ម៉ម ណៃ ត្រូវបានចៅក្រមរំឭកពីពាក្យសម្បថឲ្យនិយាយការពិត សិទ្ធិមិនធ្វើការឆ្លើយតប និងសិទ្ធិប្រឆាំងនឹងការឆ្លើយដាក់ពិរុទ្ធភាពលើខ្លួនឯង ហ្វ្រង់ស៊័រ រ៉ូ បានអះអាងថា ដោយសារតែចៅក្រមមិនទាន់បានសម្រេចលើសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ទាក់ទិននឹងការចាត់ទុកការប្រព្រឹត្តឧក្រិដ្ឋកម្មរួមជាមធ្យោយបាយនៃការទទួលខុសត្រូវសម្រាប់អង្គជំនុំជម្រះ នោះមានន័យថា ម៉ម ណៃ បានប្រឈមមុខនឹងគ្រោះថ្នាក់ ដែលថាគាត់អាចនឹងត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬក៏តុលាការជាតិ ដោយសារតែ ម៉ម ណៃ គឺជាអ្នកនៅក្រោមបង្គាប់របស់ ឌុច ដែលអាចនឹងប្រព្រឹត្តឧក្រិដ្ឋកម្មរួមជាមួយនឹង ឌុច។ រ៉ូ បាននិយាយថា លុះត្រាព្រះរាជអាជ្ញាប្រានបោលញ្ញតិស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួម ទើប ម៉ម ណៃ អាចត្រូវបានជម្រាបពីសិទ្ធិរបស់គាត់ និងអាចអនុញ្ញាតឲ្យពិភាក្សាជាមួយនឹងមេធាវីបាន។ នាពេលថ្មីៗនេះចៅក្រមបានប្រកាសថា ខ្លួននឹងចេញសេចក្តីសម្រេចស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួមស្របពេលធ្វើសេចក្តីសម្រេចលើសំណុំរឿង។*

សហព្រះរាជអាជ្ញាអន្តរជាតិ វីលៀម ស្មិត បានប្រាប់ចៅក្រមថា យោងតាមវិធានផ្ទៃក្នុងទី២៨.៤ ព្រះរាជអាជ្ញាបានជម្រាបដល់សហចៅក្រមស៊ើបអង្កេតក្នុងដំណើរការស៊ើបអង្កេតសំណុំរឿងថា ព្រះរាជអាជ្ញានឹងមិនធ្វើការកាត់ទោស ម៉ម ណៃ ឡើយ ។

ហ្វ្រង់ស៊័រ រូ បានបន្តលើកឡើងដោយកត់សម្គាល់ឃើញថា សេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាស្តីពីការប្រព្រឹត្តខុសក្រិដ្ឋកម្មរួម ត្រូវបានបង្កើតឡើងបន្ទាប់ពីមានការធ្វើជាតំណាងចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយបន្ថែមលើនេះការធ្វើជាតំណាងដើម្បីការពារ ម៉ម ណៃ ពីសំណាក់ព្រះរាជអាជ្ញានៅ អ.វ.ត.ក មិនបានការពារដល់ ម៉ម ណៃ ពីតុលាការជាតិឡើយ ។ ដោយចាប់អារម្មណ៍លើហេតុផលទាំងនេះ លោកព្រះរាជអាជ្ញាបានគូសបញ្ជាក់យ៉ាងច្បាស់ថា ភាគីរបស់ខ្លួនមិនបដិសេធចំពោះការអនុញ្ញាតឲ្យ ម៉ម ណៃ ធ្វើការពិភាក្សាជាមួយនឹងមេធាវីទេ ។ ព្រះរាជអាជ្ញាបានបន្តសង្កត់ធ្ងន់ម្តងទៀតថា ព្រះរាជអាជ្ញានឹងមិនព្យាយាមធ្វើការកាត់ទោស ម៉ម ណៃ នៅចំពោះមុខ អ.វ.ត.ក ឡើយ មិនថាចៅក្រមសម្រេចលើការប្រព្រឹត្តខុសក្រិដ្ឋកម្មរួមដោយវិធីសាស្ត្រណាក៏ដោយ ។

ក្រោយពីចៅក្រមបាននាំគ្នាពិភាក្សាមួយរយៈពេលខ្លីមក លោកប្រធានចៅក្រមបានសួរ ម៉ម ណៃ ថា តើគាត់បានពិភាក្សាជាមួយនឹងមេធាវីរបស់គាត់ហើយឬនៅ ។ ម៉ម ណៃ បាននិយាយថា គាត់មិនមានមេធាវីទេនៅពេលនេះ ប៉ុន្តែគាត់បានពន្យល់ប្រាប់ថា គាត់ធ្លាប់បានពិភាក្សាជាមួយនឹងមេធាវីម្នាក់ក្នុងអំឡុងពេលដំណើរការស៊ើបអង្កេតលើសំណុំរឿង ។ លោកប្រធានសួរ ម៉ម ណៃ ថា តើគាត់ត្រូវការមេធាវីទេ ម៉ម ណៃ បានឆ្លើយទៅវិញថា "ខ្ញុំចង់បានមេធាវីដែរ ប៉ុន្តែខ្ញុំមិនមានលទ្ធភាពជួលមេធាវីឡើយ" ។

ក្រោយពីការពិភាក្សាម្តងទៀត លោកប្រធានចៅក្រមបានផ្អាកដំណើរការនីតិវិធីនៅក្នុងថ្ងៃនេះ ។ លោកប្រធានបានកត់សម្គាល់ឃើញថា ចៅក្រមបានទាក់ទងជាមួយនឹងអង្គភាពរបស់ អ.វ.ត.ក ដែលអាចផ្តល់មេធាវីម្នាក់ជូន ម៉ម ណៃ រួចហើយ ប៉ុន្តែគោលបំណងនេះ "មិនអាចសម្រេចបាននោះទេ" ។ លោកប្រធានបន្ថែមទៀតថាដោយសារតែ ម៉ម ណៃ មិនបានពិភាក្សាជាមួយនឹងមេធាវី និងដោយសារសេចក្តីសន្និដ្ឋានពីកាប្រព្រឹត្តិខុសក្រិដ្ឋកម្មរួមត្រូវបានប្រគល់ជូនចៅក្រមរួចហើយនោះ ម៉ម ណៃ គួរតែទទួលបានឱកាសពិភាក្សាជាមួយនឹងមេធាវីជាមុនសិន មុននឹងមកធ្វើសក្ខីកម្ម ។

ការដែលថា ម៉ម ណៃ ត្រូវបានអនុញ្ញាតឲ្យមកធ្វើសក្ខីកម្មដោយគ្មានមេធាវីបានបង្កឲ្យមានបញ្ហាខ្លះ ។ បើទោះបីជាសាក្សីផ្សេងទៀតបានធ្វើសក្ខីកម្មដោយគ្មានមេធាវីក៏ដោយ ក៏សាក្សីទាំងនោះគ្រាន់តែជាសាក្សីជនរងគ្រោះដែលជ្រើសរើសមិនធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដូចជា វណ្ណ ណាត ឬដែលមិនបានដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីទាន់ពេលដូចជា នង ចាន់ផល ជាដើម ។ សាក្សីទាំងនេះមិនមែនជាអតីតបុគ្គលិកមន្ទីរស-២១ ដែលបានចូលរួមក្នុងសកម្មភាពសួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់អ្នកទោស នេះគឺជាលក្ខណៈខុសគ្នាដ៏សំខាន់រវាងសាក្សី ។ វិធានផ្ទៃក្នុងទី២៨ចែងពី«សិទ្ធិប្រឆាំងនឹងការដាក់ពិរុទ្ធភាពលើខ្លួនឯងរបស់សាក្សី» និងអនុញ្ញាតឲ្យសហចៅក្រមមេធាវី ឬចៅក្រម ផ្តល់ការធានាថា« អ.វ.ត.ក នឹងមិនធ្វើការកាត់ទោសសាក្សីដោយផ្ទាល់ឬប្រយោលឡើយ» បើទោះបីជាការកាត់ទោសមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ក៏ដោយ ។ ប៉ុន្តែ វិធាននេះមិនបានចែងថា សាក្សីក៏នឹងត្រូវបានការពារឲ្យរួចផុតពីការកាត់ទោសដោយតុលាការជាតិនោះទេ ។ វិធាននេះបានអនុញ្ញាតឲ្យសាក្សីធ្វើសក្ខីកម្មដោយសម្ងាត់ដែលអត្តសញ្ញាណ និងការរៀបរាប់របស់សាក្សីត្រូវបានរក្សាការសម្ងាត់ ។ យោងតាមវិធានទី២៨.៨ សាក្សីអាចស្នើសុំឲ្យមានដំណើរការនីតិវិធីដោយសម្ងាត់មុននឹងការឡើងមកធ្វើសក្ខីកម្មបាន ។

ដើមបណ្តឹងរដ្ឋប្បវេណីឡើងមកបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះ ដោយមានការស្នើសុំពីមេធាវីរបស់គេ ចំណែកឯសាក្សីវិញត្រូវបានកោះហៅឲ្យមកបង្ហាញខ្លួនដោយចៅក្រមដើម្បីមកធ្វើសក្ខីកម្មពីហេតុការណ៍មួយចំនួន ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានតម្រូវឲ្យស្បថមុនផ្តល់សក្ខីកម្មទេ ។ លើសពីនេះដើមបណ្តឹងរដ្ឋប្បវេណីអាចមានសិទ្ធិទាមទារសំណងបាន ។ ខុសពីដើមបណ្តឹងរដ្ឋប្បវេណី សាក្សីត្រូវតែស្បថមុននឹងចូលមកបង្ហាញខ្លួនក្នុងអង្គជំនុំជម្រះ ។ នៅក្នុងសន្និសិទ្ធិការសែតកាលពីសប្តាហ៍មុន អ្នកនាំពាក្យរបស់ អ.វ.ត.ក បាននិយាយថាផលប៉ះពាល់នៃភាពខុសគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីគឺថាចៅក្រមមិនបានផ្តល់«តម្លៃឲ្យស្មើភាពគ្នា»ដល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់សាក្សីឡើយ ។ បើទោះបីជា ម៉ម ណៃ មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែគ្រាន់តែជាសាក្សីក៏ដោយ ក៏ ម៉ម ណៃ អាចនឹងប្រឈមមុខនឹងគ្រោះថ្នាក់ជាច្រើននៅក្នុងអង្គជំនុំជម្រះនេះ ហើយអាចនឹងត្រូវលើកទឹកចិត្តឲ្យផ្តល់នូវសក្ខីកម្មមិនពិតក៏ថាបានដែរ ។ ប្រសិនបើវាជាការពិតមែនដែលថាសក្ខីកម្មរបស់សាក្សីទទួលបានតម្លៃជាងដើមបណ្តឹងរដ្ឋប្បវេណីមែននោះ វាទំនងណាស់ដែលថា ភាពសមហេតុផលនៃលក្ខណៈខុសប្លែកគ្នានេះត្រូវបានសួរដេញដោលបន្ថែមទៀតដូចជា នៅក្នុងករណីអតីតកម្មាភិបាលខ្មែរក្រហមដូច ម៉ម ណៃ ជាដើម ។

នៅក្នុងឱកាសសន្និសិទ្ធិកាសែតមួយទៀតរបស់ អ.វ.ត.ក វ៉ាន់ឌី ឡូបវើន មកពីអង្គភាពអ្នកគាំទ្រ អ្នកជំនាញ និងសាក្សីបានពន្យល់រៀបរាប់ពីសេវាកម្មទាំងអស់ដែលតុលាការផ្តល់ជូនសាក្សី ដែលរួមមានការនាំសាក្សីមកកាន់អង្គជំនុំជម្រះ រៀបចំបទពិសោធន៍របស់សាក្សី ត្រៀមសម្រាប់ការធ្វើសក្ខីកម្ម ស្តាប់ស្នងពីតម្រូវការផ្នែកការពារសុវត្ថិភាពរបស់សាក្សី និងការផ្តល់ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលផ្តល់សក្ខីកម្មជាដើម ។ លោកស្រីបានបន្តទៀតថាសាក្សីជាច្រើនមានភាពភ័យខ្លាច នឹងសាក្សីដែលជាជនដៃដល់ ដូច្នេះអង្គភាពរបស់លោកស្រីនឹងធ្វើការយកចិត្តទុកដាក់ពីបញ្ហាសុវត្ថិភាព និងសុខភាពផ្លូវចិត្តរបស់សាក្សី ។ យ៉ាងណាមិញ ការការពារតាមផ្លូវច្បាប់គឺជាបញ្ហាដាច់ដោយឡែកមួយទៀតដែលទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ ។ យោងតាមវិធានទី១១ និង១២ ទាំងផ្នែកគាំពារដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពជនរងគ្រោះបានរក្សាបញ្ជីឈ្មោះមេធាវីដែលប្រកបដោយលក្ខណៈសម្បត្តិ និងឆន្ទះក្នុងការការពារមនុស្សមានស្មារតីខ្សោយ ។

បើទោះបីជាវាទំនងថា មានការពិចារណាជាច្រើនទៅលើការការពារនិងរៀបចំសាក្សី ដែលជាជនរងគ្រោះក៏ដោយ ក៏យើងអាចមានភាពងឿងឆ្ងល់ថា តើសិទ្ធិនិងអត្ថប្រយោជន៍នៃសាក្សីជាជនរងគ្រោះត្រូវទទួលបានការកត់សម្គាល់យកចិត្តទុកដាក់ដែរឬទេ ។ ហ្វ្រង់ស៊័រ រូ និងចៅក្រមបានចូលខ្លួនការពារ ម៉ម ណៃ នៅក្នុងដំណើរនីតិវិធីក្នុងថ្ងៃនេះ ប៉ុន្តែតើមាននរណាខ្លះដែលបានគិតពីអារម្មណ៍របស់ ម៉ម ណៃ ។ ប្រសិនបើ អ.វ.ត.ក រកបានមេធាវីម្នាក់ដើម្បីផ្តល់ការណែនាំដល់ ម៉ម ណៃ នាពេលយប់នោះ នោះគាត់នឹងរៀបចំខ្លួនឆ្លើយសំណួរដោយសង្ខេបរួចជាស្រេចមុនពេលឡើងមកធ្វើសក្ខីកម្មនាពេលព្រឹកស្អែក ។ ខ្ញុំពិតជាចង់ស្តាប់នូវសក្ខីកម្មរបស់ ម៉ម ណៃ ណាស់ ។ ដោយសារតែសេចក្តីសន្និដ្ឋានស្តីពីការប្រព្រឹត្តឧក្រិដ្ឋកម្មរួម និងទំនាក់ទំនងគ្នាទៅវិញទៅមករវាង អ.វ.ត.ក និងតុលាការអន្តរជាតិមានលក្ខណៈស្មុគស្មាញ នោះខ្ញុំមានអារម្មណ៍ងាយស្រួលប្រសិនបើ ម៉ម ណៃ មិនមកធ្វើសក្ខីកម្មនាព្រឹកស្អែក ។